97 mm 100 mm 100 mm

# អំពីអង្គការ

អង្គការវេទិកាសេវាសន្តិភាពស៊ីវិល (forumZFD) គឺជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៦។ យើងកំពុងធ្វើការនៅក្នុងវិស័យបង្វែរទំនាស់នៅក្នុងប្រទេសចំនួន ១១ ដូចជានៅអឺរ៉ុប មជ្ឈិមបូព៌ា និងអាស៊ីអាគ្នេយ៍។ កម្មវិធីនៅក្នុងប្រទេសកម្ពុជាបានបើកការិយាល័យរបស់ខ្លួននៅទីក្រុងភ្នំពេញនៅឆ្នាំ ២០១៥ និងនៅខេត្តបាត់ដំបងនៅឆ្នាំ ២០១៦។

## បេសកកម្មរបស់អង្គការ

នៅក្នុងប្រទេសកម្ពុជា វិស័យនៃសកម្មភាពការងាររបស់យើងផ្តោតសំខាន់ទៅលើការសិក្សារៀនសូត្រអំពីប្រវត្តិសាស្ត្រ ការសម្របសម្រួល និងដំណើរការនៃកិច្ចសន្ទនា ហើយនិងការផ្សព្វផ្សាយវិធីសាស្ត្រនៃការបង្វែរទំនាស់ស៊ីវិល ការយល់ដឹងអំពីភាពរសើបនៃទំនាស់ និងការកសាងសន្តិភាពនៅក្នុងសង្គមមួយក្រោយបញ្ចប់សង្គ្រាម។ ដើម្បីសម្រេចបានគោលដៅ និងគោលបំណងយើងក៏បានផ្តោតយកចិត្តទុកដាក់ផងដែរទៅលើការកសាងសមត្ថភាព។

## ដៃគូរបស់អង្គការ

តាមរយៈការគាំទ្រពីបុគ្គលិកជាតិ និងអន្តរជាតិដែលមានសមត្ថភាពនោះ នាពេលបច្ចុប្បន្ននេះ យើងកំពុងតែរៀបចំកម្មវិធីរបស់យើងតាមរយៈការបង្កើតដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក សាកលវិទ្យាល័យ ទីភ្នាក់ងារនានា ក្រុមសាសនា និងជនជាតិភាគតិច ក៏ដូចជាក្រុមយុវជននានាផងដែរ។




ក្រុមការងាររបស់យើងនៅក្នុងប្រទេសកម្ពុជា

forumZFD

## ប្តេជ្ញាដើម្បីសន្តិភាព


**forumZFD**
អង្គការវេទិកាសេវាសន្តិភាពស៊ីវិល
www.forumZFD.de/en

អង្គការ **forumZFD** នៅកម្ពុជា
ការិយាល័យខេត្តបាត់ដំបង ទូរស័ព្ទ៖ +៨៥៥ ០ ៧៨ ៣៧ ៧៩ ៣៦
www.forumZFD.de/en/cambodia
E-Mail: cambodia@forumZFD.de
Facebook: www.facebook.com/forumCambodia


គណនីសម្រាប់ការបរិច្ចាគនានា៖
GLS Gemeinschaftsbank
IBAN: DE90 4306 0967 4103 7264 00
BIC: GENODEM1GLS

Bank für Sozialwirtschaft (BFS)
IBAN: DE37 3702 0500 0008 2401 01
BIC: BFSWDE33XXX

ប្តេជ្ញាដើម្បីសន្តិភាព

forumZFD




# អង្គការ **forumZFD** នៅកម្ពុជា

គម្រោងឆ្ពោះទៅរកអនាគតកាលប្រកបដោយសន្តិភាព និងនិរន្តភាព

# អំពីគម្រោង

យើងជឿជាក់ថាអនាគតកាលមួយប្រកបដោយសន្តិភាព និងនិរន្តរភាព គឺទាមទារឱ្យពលរដ្ឋកម្ពុជាទាំងអស់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់ខ្លួន និងសិក្សារៀនសូត្រអំពីប្រវត្តិសាស្ត្រទាំងនោះ។ នេះគឺជាហេតុផលដែលយើងធ្វើការគាំទ្រដល់សហគមន៍ចម្រុះនៅក្នុងសង្គមកម្ពុជា ដើម្បីសិក្សារៀនសូត្រអំពីប្រវត្តិសាស្ត្ររបស់ពួកគេ។ ដើម្បីកសាងទំនុកចិត្ត និងទំនាក់ទំនងល្អរវាងសហគមន៍នានា គឺចាំបាច់ណាស់ដែលយើងត្រូវលើកកម្ពស់ការយល់ដឹង និងគោរពទំនៀមទម្លាប់ បទពិសោធន៍ និងវប្បធម៌ផ្សេងៗ និងខុសៗគ្នា។






តំណាងសាសនាផ្សេងៗបានជួបជុំគ្នា ដើម្បីអបអរទិវាសន្តិភាពអន្តរជាតិ

## គម្រោងអប់រំសន្តិភាព

តាមរយៈគម្រោងអប់រំសន្តិភាព យើងធ្វើការជាមួយស្ថាប័នដៃគូ ដើម្បីលើកកម្ពស់ចំណេះដឹង និងជំនាញរបស់ពួកគេនៅក្នុងបរិបទបង្វែរទំនាស់។ យើងគាំទ្រដល់សហគមន៍នៅក្នុងខេត្តបាត់ដំបង ដើម្បីឱ្យពួកគេអាចធ្វើការវិភាគទំនាស់នានា និងឆ្លុះបញ្ចាំងទៅលើអាកប្បកិរិយា និងឥរិយាបថរបស់ខ្លួន ដើម្បីកាត់បន្ថយការរើសអើង និងផ្តត់គំនិតនានា។ តាមរយៈកិច្ចសហការជាមួយពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជខេត្តបាត់ដំបង (SBUBB) ដែលជាដៃគូរបស់យើង យើងរៀបចំ និងអនុវត្តវគ្គបណ្តុះបណ្តាលរយៈពេលខ្លីស្តីពីការបង្វែរទំនាស់។ យើងបណ្តុះបណ្តាលគ្រូបង្គោល ដើម្បីអាចឱ្យពួកគេយកចំណេះដឹង និងជំនាញទាំងនោះទៅបង្រៀន និងចែករំលែកជាមួយសិស្សានុសិស្ស និងសហគមន៍។



គ្រូបង្គោល SBUBB បណ្តុះបណ្តាលវគ្គខ្លីស្តីពីការយល់ដឹងទំនាស់

## គម្រោងយល់ដឹង និងចែករំលែកប្រវត្តិសាស្ត្រ

គម្រោងយល់ដឹង និងចែករំលែកប្រវត្តិសាស្ត្រមានគោលបំណងជម្រុញលើកទឹកចិត្តឱ្យពលរដ្ឋសញ្ជឹងគិតឆ្លុះបញ្ចាំងអំពីរឿងរ៉ាវផ្ទាល់ខ្លួន ឬជាសមូហភាព។

ដើម្បីបង្កើនការជឿទុកចិត្ត និងពង្រឹងទំនាក់ទំនងរវាងសហគមន៍ផ្សេងៗ គឺចាំបាច់ណាស់ដែលយើងត្រូវលើកកម្ពស់ការយល់ដឹង និងគោរពទំនៀមទម្លាប់ បទពិសោធន៍ និងវប្បធម៌ផ្សេងៗ និងខុសៗគ្នា។

គម្រោងយល់ដឹង និងចែករំលែកប្រវត្តិសាស្ត្រ ក៏មានបំណងជួយឱ្យពលរដ្ឋបញ្ចេញសម្លេង និងបង្ការការធ្វើបុរេវិនិច្ឆ័យក៏ដូចជាការរើសអើងផងដែរ។




មនុស្សមួយក្រុមធ្វើការឆ្លុះបញ្ចាំងអំពីប្រវត្តិសាស្ត្ររបស់កម្ពុជា

## គម្រោងអ្នកកសាងសន្តិភាពជំនាន់ថ្មី

គម្រោងនេះមានគោលបំណងជួយយុវជនឱ្យចូលរួមចំណែកក្នុងការកសាងសហគមន៍មួយប្រកបដោយសុខដុមនីយកម្ម។

អង្គការ forumZFD និងដៃគូរបស់ខ្លួនបានរៀបចំសកម្មភាពសិក្ខាសាលា និងការបណ្តុះបណ្តាលផ្សេងៗដល់យុវវ័យឱ្យយល់ច្បាស់អំពីសារៈសំខាន់នៃសន្តិភាព និងការរក្សាបាននូវសន្តិភាព។ យុវជនប្រើប្រាស់ចំណេះដឹងដែលខ្លួនបានទទួល ដើម្បីអប់រំបន្តដល់អ្នកផ្សេងទៀតតាមលទ្ធភាព និងទំនួលខុសត្រូវរបស់ខ្លួនម្នាក់ៗ។ យើងជឿជាក់ថាការគាំទ្រដល់យុវជនជំនាន់ក្រោយនឹងចូលរួមចំណែកជាវិជ្ជមានដល់សហគមន៍។



ក្រុមយុវជនធ្វើបដិបត្តិសមាធិ